**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

មជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺអេដស៍

សើស្បែក និង កាមរោគ

លេខ.១២៨៩...មជអសក

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ..... ឆ្នាំ ២០១៤

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**កម្មវត្ថុ** : សំណើសុំកែសំរួលនូវលក្ខ័ណ្ឌជីវសាស្រ្ត (Biological Criteria) ក្នុងការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ដែលមានចែងក្នុងគោលការណ៍ណែនាំជាតិស្តីពីការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ លើមនុស្សពេញវ័យ និង កុមារនៅប្រទេសកម្ពុជា។

**យោង** : អនុសាសន៍ របស់អង្គការសុខភាពពិភពលោក ស្តីអំពី ការប្រើប្រាស់ឱសថប្រឆាំងនឹងមេរោគអេដស៍ ឆ្នាំ ២០១៣

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើនេះ ខ្ញុំបាទសូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថាក្នុងឆ្នាំ២០១៣ អង្គការសុខភាពពិភពលោកបានផ្តល់អនុសាសន៍ថ្មី ស្តីពីលក្ខ័ណ្ឌជីវសាស្រ្តក្នុងការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ លើមនុស្សពេញវ័យ និង កុមារ ដោយបានតំឡើង កំរិតកោសិកាCD4 ដែលសមស្របសំរាប់ការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ លើមនុស្សពេញវ័យ និង កុមារ។

គោលការណ៍លក្ខ័ណ្ឌជីវសាស្រ្ត សំរាប់ចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ លើមនុស្សពេញវ័យ និង កុមារ ដែលមានចែងនៅក្នុង គោលការណ៍ណែនាំជាតិស្តីពី ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍នៅកម្ពុជាបច្ចុប្បន្ន ពុំស្របគ្នានឹងអនុសាសន៍ថ្មីរបស់អង្គការសុខភាពពិភពលោកទេ។ ដូច្នេះមជ្ឈមណ្ឌលជាតិសូមការអនុញ្ញាត កែសំរួលនូវលក្ខ័ណ្ឌជីវសាស្រ្តនេះ ដូចខាងក្រោម ៖

១. ចំពោះទារក និងកុមារផ្ទុកមេរោគអេដស៍ ដែលមានអាយុក្រោម៥ឆ្នាំទាំងអស់ ត្រូវទទួលការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ភ្លាមៗ ដោយពុំចាំបាច់រងចាំលទ្ធផល នៃការពិនិត្យគ្រាប់កោសិកា

CD4 ទេ ដើម្បីអាចកាត់បន្ថយអត្រាឈឺ និង អត្រាមរណៈរបស់ទារក និងកុមារដែលផ្ទុកមេរោគអេដស៍ អោយបានជាអតិបរមា។

២. ចំពោះមនុស្សពេញវ័យផ្ទុកមេរោគអេដស៍ ដែលជាក្រុមប្រឈមមុខខ្ពស់ តំឡើងកំរិតកោសិកា CD4 សមស្របសំរាប់ការចាប់ផ្តើមព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ពី តិចជាង រឺ ស្មើ ៣៥០កោសិកា ក្នុង១ ម.ល ទៅ កំរិតតិចជាង រឺ ស្មើ ៥០០កោសិកា ក្នុង១ ម.ល វិញ ដើម្បីចូលរួមកាត់បន្ថយការចំលងថ្មីនៃមេរោគអេដស៍ តាមរយៈការរួមភេទ។

៣. ចំពោះមនុស្សពេញវ័យផ្ទុកមេរោគអេដស៍ ដែលមានដៃគូរួមភេទមានស្ថានភាពផ្ទុកមេរោគអេដស៍ផ្ទុយ គ្នា ត្រូវទទួលការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ភ្លាមៗ ដោយពុំចាំបាច់រងចាំលទ្ធផលនៃការពិនិត្យកោសិកា CD4ទេ ដើម្បីចូលរួមកាត់បន្ថយការចំលងថ្មីនៃមេរោគអេដស៍ តាមរយៈការរួមភេទ។

៤. ចំពោះមនុស្សពេញវ័យផ្ទុកមេរោគអេដស៍ ដែលមានជំងឺរលាកថ្លើមប្រភេទបេ រួមគ្នា (HIV and HBV Co-infection) ត្រូវទទួលការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ភ្លាម ដោយពុំចាំបាច់រងចាំលទ្ធផល នៃការពិនិត្យកោសិកា CD4 ទេ។

អាស្រ័យហេតុដូចបានគោរពជូនខាងលើនេះ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាពិនិត្យ និងសំរេចដោយ អនុគ្រោះ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

វេជ្ជ. មាន_ឈីវុន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ..០០៥........អមស.ប្រជង

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៥..

ស្ថាប័ន NCHADS

ទទួល លេខ: 0054 ម៉ោង.........
ថ្ងៃទី 15 ខែ 01 ឆ្នាំ 15
បញ្ជូន:.........

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

ជំរាបជូន

**ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ**

**<u>កម្មវត្ថុ</u>** ៖ សំណើសុំកែសំរួលនូវលក្ខ័ណ្ឌជីវសាស្ត្រ (Biological Criteria) ក្នុងការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ដែលមានចែងក្នុងគោលការណ៍ណែនាំជាតិស្តីពីការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ លើមនុស្សពេញវ័យ និង កុមារនៅប្រទេសកម្ពុជា ។

**<u>យោង</u>** ៖ លិខិតលេខ ១២៨៩ មជអសក ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៤ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកប្រធានថា ក្រសួងសុខាភិបាលមិនយល់ទាស់ចំពោះ សំណើសុំកែសំរួលនូវលក្ខ័ណ្ឌជីវសាស្ត្រ (Biological Criteria) ក្នុងការចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ដែលមានចែងក្នុងគោលការណ៍ណែនាំជាតិស្តីពីការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ លើមនុស្សពេញវ័យ និង កុមារនៅប្រទេសកម្ពុជា នោះទេ ។

អាស្រ័យហេតុនេះ សូមលោកប្រធានអនុវត្តតាមសេចក្តីណែនាំថ្មីដែលក្រសួងបានសំរេច ។

សូមលោកប្រធានទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

សាស្ត្រាចារ្យ **អេង_ហួត**